នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

# ជំងឺផ្តាសាយបក្សី

## HIGHLY PATHOGENIC AVIAN INFLUENZA



អាស័យដ្ឋាន: លេខ ៧៤ មហាវិថី ព្រះមុនីវង្ស
សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (០២៣) ៤២៧ ៥៩០/ ៤២៦ ៩៧០
ទូរសារ : (០២៣) ៤២៦ ៩៧០/ ៤២៦ ១៦១

ម.ព.ឯ.ក AIDOC
Code: 230-010
Date:
Donated by:

# សេចក្តីថ្លែងអំណរគុណ

**ផ្តាសាយបក្សី** ជាជំងឺថ្មីមួយដែលមិនធ្លាប់កើតមានពីមុនមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការផ្ទុះជំងឺជាលើកដំបូង បានបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរដល់អ្នកចិញ្ចឹមបក្សី ដោយសារអត្រាស្លាប់ខ្ពស់នៅក្នុងហ្វូង និង ការកំទេចបក្សី ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ ។ មន្ត្រីបសុពេទ្យក៏បានជួបប្រទះនឹងការលំបាកយ៉ាងខ្លាំង ក្នុងការកំណត់រោគវិនិច្ឆ័យ និង វិធីសាស្ត្រក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ ដោយហេតុថា ឯកសារដែលពាក់ព័ន្ធទៅនឹងជំងឺផ្តាសាយបក្សីនេះ មានចំនួនតិចតួចបំផុត ដែលអាចរកបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា និង គ្មានឯកសារដែលពាក់ព័ន្ធទៅនឹងជំងឺផ្តាសាយបក្សី ត្រូវបានតំកល់ទុកនៅក្នុងបណ្ណាល័យរបស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

មើលឃើញភាពកង្វះខាតទាំងនេះ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាលក៏បានសំរេចចិត្តធ្វើការស្រាវជ្រាវរកឯកសារមួយចំនួនដែលទាក់ទងទៅនឹងជំងឺនេះ មកចងក្រងជាសៀវភៅស្តីពី **"ជំងឺផ្តាសាយបក្សី"** នេះឡើងដើម្បីទុកជាទុនដល់មន្ត្រីបសុពេទ្យ សំរាប់ប្រើប្រាស់ក្នុងមុខវិជ្ជាជីវៈរបស់ខ្លួន ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបានផ្តល់ឱកាសសំរាប់យើងខ្ញុំក្នុងការរៀបចំចងក្រងសៀវភៅនេះ និង សូមថ្លែងអំណរគុណចំពោះម្ចាស់ឧបត្ថម្ភថវិកាដែលមានរាយនាមដូចខាងក្រោមៈ

- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- អង្គការស្បៀង និង កសិកម្មនៃសហប្រជាជាតិ (FAO)
- មូលនិធិប្រទេសជប៉ុន (JAPAN)
- មូលនិធិអង្គការ AusAID

- មូលនិធិអង្គការ GTZ
- មូលនិធិ FRENCH COOPERATION
- មូលនិធិសាធារណៈរដ្ឋប្រជាមានិតចិន (CHINA)

យើងខ្ញុំទាំងអស់គ្នារង់ចាំទទួលការទិតៀន ស្តាបនាពីសំណាក់មិត្តអ្នកអានគ្រប់មជ្ឈដ្ឋានដោយក្តីសោមនស្សរីករាយ ។

រាល់មតិ យោបល់រិះគន់កែលំអដើម្បីស្ថាបនាទាំងអស់ សូមផ្ញើរមកៈ

**នាយកដ្ឋានផលិតកម្ម និង បសុពេទ្យាបាល**


លេខ ៧៤ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ

ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទៈ (៨៥៥-២៣) ៩៩១ ៨៧៨

ទូរសារៈ (៨៥៥-២៣) ៩៩១ ៨៧៨

ព័ត៌មានបន្ទាន់លេខៈ ០១២ ២១៤ ៩៧០


ភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤

# មាតិកា


| | ទំព័រ |
|---|---|
| និយមន័យ | ១ |
| ភ្នាក់ងារបង្កជំងឺ | ១ |
| ការរាលដាលនៃជំងឺផ្តាសាយបក្សី | ៣ |
| ការចំលង | ៣ |
| រោគសញ្ញា | ៤ |
| ការធ្វើរោគវិនិច្ឆ័យ | ៦ |
| ការធ្វើរោគវិនិច្ឆ័យប្រៀបធៀប | ៧ |
| ការព្យាបាល | ៨ |
| វិធានការការពារ | ៨ |
| វិធានជីវសុវត្ថិភាព | ១០ |
| វិធានការ ការពារនៅពេលដែលមានផ្ទុះជំងឺនៅលើទីផ្សារសត្វរស់ | ១១ |
| គ្រោះថ្នាក់ចំពោះសុខភាពសាធារណៈ | ១១ |

## និយមន័យ

ផ្តាសាយបក្សី ជាជំងឺឆ្លងដែលបង្កដោយវីរុស និង បង្កជាជំងឺលើសត្វស្លាបគ្រប់ប្រភេទ រួមទាំងមាន់ មាន់បារាំង មាន់ទោ ក្រួច ទា ក្ងាន និង បក្សីផ្សេងទៀត ។ នៅក្នុងវិស័យចិញ្ចឹមសត្វតាមបែបឧស្សាហកម្ម មាន់ពង ជាប្រភេទដែលទទួលការចំលងខ្លាំងជាងគេ ។ សត្វស្លាបដែលរស់នៅជាសេរី អាចមានវីរុសនៃជំងឺផ្តាសាយនៅក្នុងខ្លួន តែពួកវាពុំឈឺទេ ដោយសារមានភាពស៊ាំធម្មជាតិក្នុងខ្លួន ។ ពពួកសត្វព្រៃ-សត្វស្លាបទឹកជាប្រភពមេរោគ និង អាចជាអ្នកនាំមកនូវការចំលងដល់សត្វស្លាបក្នុងស្រុក ។ វីរុសនៃជំងឺផ្តាសាយបក្សីភាគច្រើន ត្រូវបានគេរកឃើញនៅលើសត្វទា ច្រើនជាងប្រភេទសត្វផ្សេងទៀត ។

## ភ្នាក់ងារបង្កជំងឺ

វីរុសផ្តាសាយបក្សីជា RNA វីរុស ក្នុងគ្រួសារ *Orthomyxoviridae* ប្រភេទ *Influenza* ក្រុម (Type) A ពូជបក្សី ។ ដោយផ្អែកលើទំនាក់ទំនងរបស់អង់ទីសែនដែលមានលើស្រោមខាងក្រៅរបស់វីរុសដូចជាៈ glycoprotein haemagglutinin (H) និង neuraminidase (N) បច្ចុប្បន្ន វីរុសនៃជំងឺផ្តាសាយបក្សី ត្រូវបានបែងចែកជាច្រើនអនុក្រុម ដូចជាអនុក្រុម H ដែលមានពី $H_1$ ដល់ $H_{15}$ និង អនុក្រុម N ពី $N_1$ ដល់ $N_9$ ។ អនុក្រុម $H_5N_2$ បានធ្វើអោយផ្ទុះជំងឺយ៉ាងធ្ងន់ធ្ងរនៅអាមេរិក ឆ្នាំ១៩៨៣-៨៤ និង នៅ Mexico ឆ្នាំ ១៩៩៤ ។ ជាប្រវត្តិសាស្ត្រ អនុក្រុម $H_5$ និង $H_7$ ជាប្រភេទវីរុសដែលមានឥទ្ធិពលខ្លាំងជាងគេ និង បង្កជំងឺជាញឹកញាប់លើបក្សី ។ វីរុសផ្តាសាយ ដែលបង្កជំងឺលើសត្វស្លាប អាចត្រូវបានចែកដោយផ្អែកលើភាពដែលអាចបង្កជំងឺរបស់វា ។ វីរុស ដែលមានភាពបង្កជំងឺខ្លាំងក្លា (HPAI- highly pathogenic avian influenza) អាចបណ្តាលឱ្យអត្រាសត្វស្លាប់រហូតដល់ ៨០-៩០% ជួនកាល ១០០% ។ នៅលើពិភពលោកមានរបាយការណ៍ជាច្រើន ដែលបានបរិយាយអំពីការផ្ទុះជំងឺ ដែលបង្កឡើងដោយវីរុសប្រភេទនេះ នៅលើសត្វស្លាបស្រុក ចាប់តាំងពីឆ្នាំ ១៩៥៩ ។ ករណីធ្ងន់ធ្ងរ កើតមាននៅប្រទេស




*គំនូសបំព្រួញទី ១: រូបផ្គុំទូទៅនៃវីរុសជំងឺផ្តាសាយបក្សី*

អ៊ីតាលី នៅឆ្នាំ ១៩៩៩/២០០០ ដែលមានការផ្ទុះជំងឺ ៤១៣ ដង និង មានសត្វឆ្លងជំងឺ ១៦លានក្បាល ។ ជំងឺផ្តាសាយបក្សីអាចកើតមាននៅលើសត្វស្លាបដោយពុំមានផ្តល់សញ្ញាសំគាល់ណាមួយឡើយ និង ឆ្លងរាលដាលពីទ្រុងមួយទៅទ្រុងមួយទៀតយ៉ាងឆាប់រហ័ស ។ វីរុសផ្តាសាយក្នុងអនុក្រុមខ្លះបង្កជាជំងឺក្នុងសភាពស្រាល (LPAI- low pathogenic avian influenza) ។ រោគសញ្ញានៃជំងឺ អាចមានតិចតួច ឬ គ្មានតឹកតាងអ្វីទាំងអស់ ហើយអត្រាស្លាប់មានកំរិតទាបបំផុត។ ប៉ុន្តែប្រភេទខ្លះនៃពពួក LPAI បន្ទាប់ពីបានជ្រៀតចូលទៅក្នុងខ្លួនបក្សីមួយរយៈមក អាចវិវឌ្ឍន៏ទៅជា HPAI ។ ជួនកាល ការចំលងដោយមេរោគផ្សេងទៀត ឬ លក្ខខណ្ឌបរិស្ថាន អាចជំរុញឱ្យការចំលងដោយប្រភេទ LPAI ក្លាយទៅជាជំងឺដ៏ធ្ងន់ធ្ងរ ។

អុនក្រុម $H_7N_2$ ត្រូវបានគេរកឃើញនៅលើមាន់ស្រែនៅឆ្នាំ ១៩៩៦-៩៧ ។ វាមិនបណ្តាលឱ្យមាន់ឈឺទេ តែវាបង្កគ្រោះថ្នាក់ដ៏ធំទៅលើឧស្សាហកម្មបក្សី ។ រហូតមកទល់ពេលនេះ ភាគច្រើននៃអនុក្រុម $H_5$ និង $H_7$ អាចបង្កអោយមានជំងឺធ្ងន់ធ្ងរ ។ វីរុស មានបរិមាណច្រើននៅក្នុងលាមក និង អាចរស់បានយូរ ។ ក្នុងមួយក្រាមនៃលាមក ដែលផ្ទុកមេរោគអាចបង្កការចំលងទៅបក្សីចំនួន ១០លានក្បាល ។ វីរុសជំងឺផ្តាសាយបក្សី អាចមាននៅលើសំបកស៊ុត ផ្នែកក្រហម និង សនៃស៊ុតបក្សី ។ នៅសីតុណ្ហភាព ៦៥-៧០ អង្សាសេ